## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ៣៨០ប្រ
ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩៨
**<u>សាលដីកា</u>**
លេខៈ២៩
ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ......... ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក ........... ជាចៅក្រម
៤-លោក ............ ជាចៅក្រមរបាយការណ៍
៥-លោក ............. ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-លោក ................

**<u>តំណាងមហាអយ្យការ</u>**

-លោក ............... ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្ដឹងសាទុក្ខពីសាលដីកាលេខ៧១៦ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៣៨៦ប្រ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្ដឹងសាទុក្ខឈ្មោះខគ ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិ ខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅភូមិត្រពាំងចំបក់ ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ ។ ឪពុក ឈ្មោះគិន ជី "រ" ម្ដាយឈ្មោះម៉ាក់ ប៊ុន "រ" ប្រពន្ធឈ្មោះឈា សុខចេង ។

និងចុងបណ្ដឹងសាទុក្ខឈ្មោះឈឈ ភេទប្រុស អាយុ ៧០ឆ្នាំ ជាតិ ខ្មែរមុខរបរ ធ្វើស្រែ ទីលំនៅភូមិត្រពាំងចំបក់ ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ ។ ឪពុកឈ្មោះឈា "ស" ម្ដាយឈ្មោះប៉ា "ស" ប្រពន្ធឈ្មោះ អ៊ុន ហ៊ី ។

**<u>កម្មវត្ថុបណ្ដឹង</u>** ប្ដឹងសុំកិច្ចការប្រញាប់បើកផ្លូវចេញ-ចូល។

បានឃើញបណ្ដឹងសាទុក្ខលេខ៤០១ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់លោកខគ បានប្ដឹងមិនសុខចិត្តនឹងសេចក្ដីសម្រេច នៃសាលដីកាលេខ៧១៦ ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣៨០ប្រ.ចុះថ្ងៃទី១១ខែធ្នូ ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងសុំកិច្ចការប្រញាប់ ចុះថ្ងៃទី ១៥.៧.៩៨ របស់ដើមចោទឈ្មោះឈឈ ប្ដឹងសុំបើកច្រកផ្លូវពីខាងត្បូងដោយសំអាងហេតុថា ឈ្មោះខគ មិនឱ្យខ្លួនដើរកាត់ដីមុខផ្ទះចូលទៅធ្វើស្រែតាមខ្លឹមសារ នៃសាលក្រមលេខ០៣(ក) ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ ១៩៩៨ របស់តុលាការខេត្តតាកែវឡើយ ។ ហើយលើកទី ១ នៅថ្ងៃទី ២១-៦-៩៨ ខ្លួនបាននាំក្មួយទៅមើលស្រែ ត្រូវឈ្មោះខគ និង ប្រពន្ធហាមឃាត់មិនឱ្យចូល ។ ជាលើកទី២ នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៨ ខ្លួនបាននាំបងប្អូនកូនក្មួយចូលទៅក្ខុរស្រែក៏ត្រូវឈ្មោះខគ ហាមឃាត់ដាច់ខាតមិនឱ្យចូលទៅក្ខុរឡើយ ហើយថែមទាំងទាញទ្វាររបងបិទទៀតផង ។

បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខ០៥ប្រ.៩៨ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨របស់តុលាការខេត្តតាកែវ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹងកិច្ចការប្រញាប់ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៨ របស់ដើមចោទឈ្មោះ ឈឈ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- សម្រេចជាបន្ទាន់អនុញ្ញាតឱ្យឈ្មោះឈឈ (ដើមចោទ) បើកផ្លូវចេញ-ចូល ជាបណ្តោះអាសន្ន នៅដីកម្មសិទ្ធិរបស់ខ្លួនពីជ្រុងខាងត្បូង ដោយចូលពីផ្លូវលំសំដៅទៅដីនោះ ។

៣- សម្រេចរឹបអូសប្រាក់ប្រដាប់ក្តីចំនួន២០០០៛ ពីឈ្មោះឈឈ ដែលបានបង់ទុករួច ។

-ដីកានេះ មានអានុភាពអនុវត្តន៍ភ្លាមៗ ទោះបីមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

-ដីកានេះ សម្រេចចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់៦០ថ្ងៃ គិតចាប់តាំងពីថ្ងៃទទួលដំណឹង ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ២៧ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៨ របស់លោកខគ ដែលប្តឹងជំទាស់នឹងដីកាសម្រេចកិច្ចការប្រញាប់លេខ០៥ប្រ.៩៨ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨ របស់ តុលាការខេត្តតាកែវ នៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧១៦ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៦-៨-៩៨ របស់ឈ្មោះខគ ទុកជាត្រឹមត្រូវ តាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់ដីកសម្រេចកិច្ចការប្រញាប់លេខ០៥ប្រ.៩៨ ចុះថ្ងៃទី២៣.៧.៩៨ របស់តុលាការ ខេត្តតាកែវ ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍គឺពន្ធចុះបញ្ជីនិងពន្ធហ៊ឹង២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀលចំណាយលើកិច្ចប្រគល់ដីកាកោះ៥.០០០រៀលនិងលើអាជ្ញាធរតុលាការ៥០០០រៀល សរុប ១៣.០០០រៀល ។

៤- សាលដីកានេះ មានអានុភាពអនុវត្តភ្លាមៗ ទោះជាមានបណ្តឹងសាទុក្ខក៏ដោយ ។

៥- សាលដីកានេះ ជំនុំជំរះនឹងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

បានឃើញបណ្តឹងសាទុក្ខលេខ៤០១ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់លោកខគ បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៧១៦ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍លើ សេចក្តីសម្រេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី២០-០៧-១៩៩៩ របស់ឈ្មោះខគ

បានឃើញសារណា ចុះថ្ងៃទី១៧-០៨-១៩៩៩ របស់ឈ្មោះឈឈ

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-បណ្តឹងសាទុក្ខរបស់ចុងចម្លើយស្ថិតនៅក្នុងកំណត់ច្បាប់គប្បីលើកយករឿងនេះមកពិនិត្យពិចារណា។

-សាលដីការដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍បានសម្រេចត្រឹមត្រូវតាមគតិច្បាប់ហើយ ។

-បានស្តាប់ចម្លើយរបស់ឈ្មោះខគ ជាចុងចម្លើយ និងជាម្ចាស់បណ្តឹងសាទុក្ខនៅ ពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា៖ បានជាខ្លួនប្តឹងសាទុក្ខ ព្រោះថា ផ្លូវដែលគាត់ដើរចេញ-ចូលនោះអស់រយៈពេល ១៥ឆ្នាំហើយ ដែលអាចធ្វើឱ្យប៉ះពាល់ខូចដល់

ផលប្រយោជន៍ដំណាំរបស់ខ្លួនច្រើន ហើយដីរបស់គាត់ គឺស្ថិតនៅក្នុងរបងដីរបស់ខ្លួន។ ប៉ុន្តែក្នុងមួយឆ្នាំគាត់ចូលទៅធ្វើស្រែតែមួយម្តង មិនដែលចូលធ្វើស្រែរាល់ថ្ងៃទេ។ សំណូមពរ សូមបដិសេធកិច្ចការប្រញាប់ចោល ។

បានស្តាប់ចម្លើយរបស់ឈ្មោះឈឈ ជាដើមចោទ និងជាចុងបណ្តឹងសាទុក្ខនៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា នៅឆ្នាំ១៩៧៩ ខ្លួនបានកាន់កាប់ដីនេះ ហើយក្រោយមកនៅឆ្នាំ១៩៨៣ទើបឃុំបានបែងចែកដីមកឱ្យខ្លួន ក្រោយមកខ្លួនបើកផ្លូវដើម្បីចេញ-ចូលធ្វើស្រែពេលនោះគេបានធ្វើរបងបិទប៉ុន្តែគេឱ្យខ្លួនដើរចេញ-ចូលឆ្នាំតាមផ្ទះគេ បន្ទាប់មកទៀតគេមិនឱ្យខ្លួនចេញ-ចូលតាមផ្ទះគេទៀត ទើបខ្លួនសុំបើកផ្លូវចាស់ដើម្បីចេញ-ចូល ធ្វើស្រែ តែត្រូវគេគំរាមរកវាយ ទើបខ្លួនប្តឹងទៅតុលាការខេត្តតាកែវ នៅពេលស្រូវទុំ សុំគេចូលទៅច្រូតស្រូវ តែគេមិនឱ្យចូល ដែលនាំឱ្យខូចខាងផលប្រយោជន៍របស់ខ្លួនអស់ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៩០១ ចុះថ្ងៃទី២០-១១-៩៨ របស់លោកខគ ស្ថិតក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះ បានតាមមាត្រា១៤ នៃច្បាប់ស្តីពីការ ចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលតុលាការថ្នាក់ក្រោមក៏ដូចសាលាឧទ្ធរណ៍ដែរ ដែលសម្រេចបើកផ្លូវឱ្យដើមចោទចេញចូលបណ្តោះអាសន្ន ទៅកាន់ដីរបស់ខ្លួនពីជ្រុងខាងត្បូងដោយចូលពីផ្លូវលំទៅនោះជាការត្រឹមត្រូវហើយ ពីព្រោះថា ច្រកនេះពុំមានប៉ះពាល់ផលប្រយោជន៍ចុងចម្លើយ ឬ ក៏ជនដទៃណាមួយទេហើយក៏ជាច្រកចាំបាច់បំផុតក្នុងការចេញចូលទៅបង្កបង្កើនផលគ្រប់រដូវរបស់ដើមចោទទៀតផង ។ ម្យ៉ាងទៀតដែលដើមចោទសុំបើកចេញចូលទៅបង្កបង្កើនផលនេះ ក៏ជាដីដែលសាលក្រមស្ពាពរលេខ០៣"គ" ចុះថ្ងៃទី១៣-០១-៩៨ របស់តុលាការខេត្តតាកែវសម្រេចឱ្យដើមចោទរួចហើយដែរ ។

-យល់ឃើញថា សារណាលើកឡើងរបស់ចុងចម្លើយថា ដើមចោទបានទៅកាប់បំផ្លាញ របងខ្លួននាំឱ្យខ្លួនខូចខាតផលប្រយោជន៍នោះពុំមានភស្តុតាងណាមួយបញ្ជាក់ពីហេតុផលនេះទេ គឺមានតែក្នុង ចម្លើយទេដែលបង្កឱ្យដើមចោទខកខានទៅធ្វើស្រែរបស់ខ្លួនរហូតដល់ ៤រដូវ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៧១៦ ចុះថ្ងៃទី១៩-១១-៩៨ របស់សាលា ឧទ្ធរណ៍ដែលសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ៩០១ ចុះថ្ងៃទី២០-១១-៩៨ របស់លោកខគ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ៧១៦ចុះថ្ងៃទី១៩-១១-៩៨របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តី ដែលលោកឈឈ បានបង់ជួសនៅតុលាការកំពូល ចំនួន១៩០០០រៀល គឺ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់រើបប្រាក់

-ចំណាយក្នុងការប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប១៩០០០រៀល ។

ហើយតម្រូវឱ្យលោកខគ សងប្រាក់១៩០០០រៀលនេះ ទៅលោកឈឈ វិញ ។
៤-សាលដីកានេះ របសាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែកវ ឆ្នាំ២០០៣ ។